# ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ៖ ការពង្រឹងសេរីភាពខាងការបញ្ចេញមតិ



មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែកក្កដា ឆ្នាំ២០២១

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃអង្គការផ្លាស់ប្តូរសេរីភាពខាងការបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពខាងការបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃសម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ (CIVICUS) ព្រមទាំងជាសមាជិកអង្គការប្រឆាំងទារុណកម្មពិភពលោក ( OMCT SOSTorture Network) និងជាសមាជិក OECD Watch ផងដែរ។

គេហទំព័ររបស់សិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិនិងសេរីភាព" និងទទួលពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងនិងផ្លាស់ប្តូរសង្គម នៅសកលវិទ្យាល័យឃ្វីនឡែនទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។

## សេចក្តីថ្លែងអំណរគុណ

ម.ស.ម.ក សូមថ្លែងអំណរគុណចំពោះអង្គការដៃគូ ស្ថាប័នផ្សព្វផ្សាយ និងជាពិសេសយុវជនមកពីមជ្ឈដ្ឋានផ្សេងៗគ្នា ដែលបានចូលរួមក្នុងកិច្ចពិភាក្សាក្រុមទាំងផ្ទាល់ និងអនឡាញ និងបានផ្តល់នូវជាតុចូលដ៏មានសារសំខាន់ដើម្បីកំណត់នូវប្រធានបទទាក់ទងនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។

## អំពីមេរៀនស្តីពីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

មេរៀនស្តីពីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ("មេរៀន") គាក់តែងឡើងជាផ្នែកមួយនៃគម្រោងលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា ក្នុងគោលបំណងបង្ហាញអំពីតួនាទីដ៏សំខាន់របស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងការពង្រឹងសេរីភាពខាងការបញ្ចេញមតិ។ មេរៀននេះនឹងពន្យល់នូវតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក៏ដូចជាច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលត្រូវអនុវត្តផងដែរ។

បន្ថែមពីនេះ មេរៀននេះក៏លើកឡើងនូវបញ្ហាប្រឈមរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជារួមមាន ភាពផ្តាច់មុខនៃប្រព័ន្ធផ្សព្វផ្សាយ និងការរឹតត្បិតផ្នែកច្បាប់ចំពោះស្ថាប័នផ្សព្វផ្សាយឯក រាជ្យ។ ហើយមេរៀននេះក៏លើកឡើងអំពីសារៈសំខាន់នៃតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យសម្រាប់ពលរដ្ឋនិងសង្គមផងដែរ។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមទាក់ទងនឹងមេរៀននេះ សូមទាក់ទងមកកាន់ ម ក.ម.ស.តាមរយៈអាសយដ្ឋាន៖

ផ្ទះ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរស័ព្ទ៖ +៨៥៥ ២៣ ៧២ ៦៩ ០១ (០)

គេហទំព័រ៖ www.cchrcambodia.org

CC BY NC SA

## មាតិកា


១. សេចក្ដីផ្ដើម ........................................................................................................ ១

២. តើអ្វីទៅជា“ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ”? ........................................................................ ១

៣. ក្របខ័ណ្ឌច្បាប់ និងការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ...................................................២

៤. បញ្ហាប្រឈមចំពោះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា ............................................................ ៣

៤.១. ភាពផ្ដាច់មុខនៃប្រព័ន្ធផ្សព្វផ្សាយ ........................................................................... ៣

៤.២. ការរឹតត្បិតផ្នែកច្បាប់លើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា ............................................ ៤

៥. ហេតុអ្វីការទទួលបានប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមានសារៈសំខាន់? ............................................ ៧

# ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ៖
# ការពង្រឹងសេរីភាពខាងការបញ្ចេញមតិ

## ១ .សេចក្ដីផ្ដើម

ប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យ គឺជាផ្នែកមួយដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ផ្សព្វផ្សាយចំណេះដឹង ទស្សនៈ និងគំនិតនានាដែលមានភាពចាំបាច់សម្រាប់ការអភិវឌ្ឍសង្គម ហើយនេះក៏ជាសមត្ថភាពរបស់បុគ្គលម្នាក់ៗក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនផងដែរ។ វិស័យប្រព័ន្ធផ្សព្វផ្សាយដែលមានភាពរឹងមាំ ចម្រុះ និងឯករាជ្យ គឺជាកត្តាកែតម្រូវដ៏ចាំបាច់មួយចំពោះការរំលោភអំណាច អំពើពុករលួយ និងកង្វះខាតតម្លាភាពនៅក្នុងសង្គម។




## ២. តើអ្វីទៅជា "ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ"?

ប្រព័ន្ធផ្សព្វផ្សាយសំដៅទៅលើសារព័ត៌មាន វិទ្យុ ទូរទស្សន៍ អ៊ិនធឺណិត និងបណ្ដាញផ្សព្វផ្សាយសង្គមផ្សេងៗទៀត។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យសំដៅទៅលើប្រព័ន្ធផ្សព្វផ្សាយទាំងឡាយណា ដែលមិនស្ថិតក្រោមឥទ្ធិពលរបស់រដ្ឋាភិបាល ឬក្រោមផលប្រយោជន៍ខាងផ្នែកសាជីវកម្មណាមួយឡើយ។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យធានាថាព័ត៌មានដែលពលរដ្ឋបានទទួលគឺអាចទុកចិត្តបាន និងមិនលម្អៀងដោយសារកត្តាផលប្រយោជន៍ពីខាងក្រៅឡើយ។ ដូច្នេះព័ត៌មានឯករាជ្យ គឺចាំបាច់ណាស់សម្រាប់ការអភិវឌ្ឍសង្គម នយោបាយ និងសេដ្ឋកិច្ច។[1]

ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមានភាពចាំបាច់ ដើម្បីឱ្យសេរីភាពសារព័ត៌មានកាន់តែមានភាពប្រាកដប្រជា។ ប្រព័ន្ធផ្សព្វផ្សាយសេរី គឺជាកត្តាចាំបាច់ដើម្បីធានានូវសេរីភាពនៃគំនិត និងសេរីភាពខាងការបញ្ចេញមតិ ហើយនេះក៏ជាគ្រឹះមួយសម្រាប់សង្គមប្រជាធិបតេយ្យ។ សេរីភាពខាងការបញ្ចេញមតិគឺមានភាពចាំបាច់ដើម្បីធានានូវសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ បើគ្មានសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយសេរីទេ សង្គមមិនអាចធ្វើឱ្យរដ្ឋាភិបាលមានទំនួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនឡើយ ហើយលើសពីនេះទៀត លទ្ធិប្រជាធិបតេយ្យពិតប្រាកដក៏មិនអាចកើតមានឡើយ។ ដើម្បីបំពេញគោលដៅរបស់ខ្លួនក្នុងការផ្ដល់នូវមតិសាធារណៈ សារព័ត៌មានគួរតែអាចប្រាស្រ័យទាក់ទង និងបញ្ចេញមតិរបស់ខ្លួនបានដោយសេរី ទៅលើព័ត៌មាន និងគំនិតនានា ដោយគ្មានការត្រួតពិនិត្យ ឬការរឹតត្បិតតាមមធ្យោបាយណាមួយឡើយ។

[1] អង្គការយូណេស្កូ ប្រព័ន្ធផ្សព្វផ្សាយ សេរី ឯករាជ្យ និងចម្រុះភាព ទំព័រ ២ (២០១៤)

## ៣ .ក្របខ័ណ្ឌច្បាប់ និងការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ




មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។[2] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញបានចែងថា "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពការជួបជុំ"។[3] បន្ថែមពីនេះទៀត មាត្រា ១ នៃច្បាប់ស្តីពីរបបសារព័ត៌មាននៅកម្ពុជាបានធានាថា សេរីភាពសារព័ត៌មាន និងសេរីភាពនៃការបោះពុម្ពផ្សាយឱ្យបានសមស្របតាមមាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។[4]

ដូចគ្នានេះដែរ មាត្រា ១៩ កថាខណ្ឌ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថាជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្វែងរកព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬ បោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។[5]

រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីរបបសារព័ត៌មាននៅកម្ពុជាការពារដាច់ខាតនូវប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដើម្បីឱ្យប្រជាពលរដ្ឋខ្មែរអាចប្រើសិទ្ធិរបស់ខ្លួនក្នុងការបង្កើតប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក៏ដូចជាមានសិទ្ធិសេរីភាពក្នុងការទទួលបាននូវប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។

បន្ថែមពីនេះ សេចក្តីពន្យល់ទូទៅលេខ ៣៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៃគណៈកម្មាធិការសិទ្ធិមនុស្ស បានបញ្ជាក់យ៉ាងច្បាស់ពីមធ្យោបាយនានាដែលរដ្ឋជាសមាជិកត្រូវអនុវត្តដើម្បីការពារសិទ្ធិរបស់អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសដើម្បីលើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនិងចម្រុះ។ ដូច្នេះ រដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការលើកកម្ពស់ និងធានា

[2] មាត្រា ៣១ កថាខណ្ឌ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[3] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[4] មាត្រា ១ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

[5] មាត្រា ១៩ កថាខណ្ឌ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ឱ្យមានប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងឯករាជ្យជាពិសេសពិចារណាលើការការពារស្របច្បាប់ដែលត្រូវជានាចំពោះវិស័យសារព័ត៌មាន និងប្រព័ន្ធ ផ្សព្វផ្សាយឯករាជ្យ។[6]

## ៤ .បញ្ហាប្រឈមចំពោះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា

### ៤ .១.ភាពផ្តាច់មុខនៃប្រព័ន្ធផ្សព្វផ្សាយ




ការក្តោបក្តាប់ផ្តាច់មុខលើប្រព័ន្ធផ្សព្វផ្សាយដោយម្ចាស់ក្រុមហ៊ុនឯកជនពីរឬបី អាចជាកត្តារាំងស្ទះដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងការដើរតួនាទីជាអ្នកឃ្លាំមើលទាក់ទងនឹងការអនុវត្ត ឬការរំលោភអំណាចទាំងក្នុងវិស័យ សាធារណៈនិងឯកជន។ នៅបណ្តាប្រទេសដែលអាជ្ញាធរជាម្ចាស់ ឬជាអ្នកគ្រប់គ្រង និងរៀបចំប្រព័ន្ធផ្សព្វផ្សាយ ក្រុមអ្នកនយោបាយជំទាស់អាចនឹងមិនត្រូវបានគេផ្តល់ឱកាសក្នុងការស្វែងរកសំឡេងគាំទ្រ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនៅពេលបោះឆ្នោតត្រូវបានរៀបចំ ដែលនេះអាចជាការសម្រេចលើលទ្ធផលនៃការបោះឆ្នោត ហើយសាធារណជនអាចនឹងមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្ហាញនូវក្តីបារម្ភទៅកាន់តំណាងរបស់ខ្លួន ឬសាធារណៈឡើយ។[7] ជាលទ្ធផល សំឡេងជំទាស់របស់សាធារណជននឹងត្រូវរាំងខ្ទប់ដោយភាពផ្តាច់មុខនៃប្រព័ន្ធផ្សព្វ ផ្សាយ។ ដូច្នេះសេរីភាពខាងការបញ្ចេញមតិនឹងត្រូវបានរឹតត្បិតដោយសារភាពផ្តាច់មុខនៃប្រព័ន្ធផ្សព្វផ្សាយ។

នៅប្រទេសកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិកភាគច្រើនដូចជា វិទ្យុ និងទូរទស្សន៍មានជាប់ទាក់ទងជាមួយគណបក្សកាន់អំណាច ឬត្រូវបានគ្រប់គ្រងដោយមនុស្សដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋាភិបាល។ នេះបង្កើតឱ្យមានបរិយាកាសមួយដែលភាពចម្រុះនៃមតិមិនត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ នៅក្នុង វិស័យទូរទស្សន៍ និងវិទ្យុ ការប្រកួតប្រជែងទីផ្សារសេរីមានលក្ខណៈតិចតួចក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ជាពិសេសបន្ទាប់ពីមានការបង្ក្រាបរបស់រដ្ឋាភិបាលក្នុងឆ្នាំ ២០១៧ ដែលកាលនោះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមួយចំនួនត្រូវបានបង្ខំឱ្យបញ្ឈប់ប្រតិបត្តិការ។[8] ទូរទស្សន៍ និងវិទ្យុត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹង ក៏ប៉ុន្តែសម្រាប់ពេលបច្ចុប្បន្ននេះ ភាពចម្រុះនៃមតិយោបល់នៅតែមាននៅលើបណ្តាញសង្គម។ ទោះយ៉ាងណាក៏ដោយ អ្នកប្រើប្រាស់បណ្តាញផ្សព្វផ្សាយ

---

[6] សេចក្តីពន្យល់ទូទៅ លេខ ៣៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៃគណៈកម្មាធិការសិទ្ធិមនុស្ស

[7] ក្រសួងការបរទេសណរវ៉េយ ស្តីពីកិច្ចខិតខំប្រឹងប្រែងអន្តរជាតិដើម្បីលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ( <https://www.regjeringen.no/en/topics/foreign-affairs/human-rights/ny-struktur/promote_freedom/id2358336/>.)

[8] ខនរ៉ាដ អាដេណូ ស្ទីហ្វទុង ស្តីពីសេរីភាពសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសកម្ពុជា ទំព័រ៨ (២០១៥)

សង្គមទាំងនោះត្រូវបានតាមដាន និងបំភិតបំភ័យដោយរដ្ឋាភិបាល។ ដូច្នេះលំហូរព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ត្រូវបានរឹតត្បិតសម្រាប់សាធារណជន នៅពេលដែលភាពផ្តាច់មុខនៃប្រព័ន្ធផ្សព្វផ្សាយបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។

## ៤.២. ការរឹតត្បិតផ្នែកច្បាប់លើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា



ការរឹតត្បិតផ្នែកច្បាប់ទៅលើប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យ នៅកម្ពុជាបានរារាំងសមត្ថភាពរបស់ពួកគេក្នុងការប្រតិបត្តិការ ប្រកបដោយបរិយាកាសសុវត្ថិភាព។ ទោះយ៉ាងណាក៏ដោយ មានក្របខ័ណ្ឌច្បាប់មួយចំនួនដែលគាំទ្រដល់វិស័យនេះ។ ខាងក្រោមនេះជាការពិពណ៌នាអំពីការរឹតត្បិតផ្នែកច្បាប់ក្នុងការដំណើរការប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យនៅក្នុងប្រទេសកម្ពុជា។

ច្បាប់ស្តីពីរបបសារព័ត៌មាននៅប្រទេសកម្ពុជា កំណត់ថាសារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយញុះញង់ដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា។[9] សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ។[10] សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ។[11] វាក្យស័ព្ទទូលំទូលាយ និងមិនច្បាស់លាស់ទាំងនេះរារាំងដល់ការរិះគន់ចំពោះមន្ត្រី និងស្ថាប័នសាធារណៈ។ ច្បាប់ស្តីពីរបបសារព័ត៌មាននៅកម្ពុជាក៏ចែងផងដែរថា "សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តការមិនពិតដែលជាការជេរប្រមាថ ការមើលងាយដល់ស្ថាប័នជាតិ ។[12]

ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ិនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តថាគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ក្រោមប្រការ ៦ខ និង ៦គ ដែលចែងថាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានសិទ្ធិអំណាច "បិទគេហទំព័រ និង (page) ទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម" ដែលត្រូវបានរកឃើញថាកំពុងផ្សព្វផ្សាយមាតិកាល្មើស ឬ "ផ្សព្វផ្សាយព័ត៌មានដោយចេតនាដើម្បីបង្កជាចលាចលក្នុងសង្គម"។[13] ក្រសួងតម្រូវឱ្យ "ក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតទាំងអស់ដែលកំពុងប្រតិបត្តិការធ្វើអាជីវកម្មនៅក្នុងព្រះ

---

[9] មាត្រា ១១ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

[10] មាត្រា ១២ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

[11] មាត្រា ១៤ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

[12] មាត្រា ១៣ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

[13] ប្រកាសអន្តរក្រសួងស្តីពី ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ិនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា ប្រកា៦

រាជាណាចក្រកម្ពុជា មានកម្មវិធី សុហ្វវែ និងបំពាក់ឧបករណ៍គ្រប់គ្រងអ៊ិនធឺណិតដើម្បីងាយស្រួលក្នុងការច្រោះ (Filter) ឬធ្វើការរាំងខ្ទប់(Block) ចំពោះគេហទំព័រ គណនី (Account) ឬ ទំព័រ (Page) របស់ប្រព័ន្ធផ្សព្វផ្សាយសង្គមណាដែលត្រូវបានចាត់ទុកថាខុសច្បាប់"។[14] ក្រសួងមហាផ្ទៃទទួលបន្ទុកក្នុងការកំណត់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់រាល់ គេហទំព័រ និងគណនីរបស់ប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងឡាយណា ដែលផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ និងផ្សព្វផ្សាយដោយខុសច្បាប់ ដែលល្មើសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[15]

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថាការបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមរយៈសារព័ត៌មានត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន។[16] បទប្បញ្ញត្តិដែលត្រូវបានប្រើជាញឹកញាប់ដើម្បីបំបិទសិទ្ធិសេរីភាពខាងការបញ្ចេញមតិគឺមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) និងមាត្រា ៤៩៥ (បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍)។ បទប្បញ្ញត្តិទាំងនេះរួមគ្នា ធ្វើឱ្យមានការដាក់ទោសចំពោះការអនុវត្តនូវសេរីភាពមូលដ្ឋាន ជាពិសេសសេរីភាពខាងបញ្ចេញមតិ។ មាត្រា៤៩៤ ចែងថា ការញុះញង់អាចត្រូវផ្តន្ទាទោសកាលបើអំពើនេះត្រូវបានប្រព្រឹត្តៈ សំណេរ ឬគំនូរប្រភេទណាក៏ដោយដែលត្រូវផ្សព្វផ្សាយក្នុងចំណោមសាធារណជន ឬតាំងឱ្យសាធាណជនមើល ឬដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។[17] មាត្រា ៤៩៥ ចែងថា "អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយមានចែងក្នុងមាត្រា ៤៩៤" នៃក្រមនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ទៅ ៤.000.000 (បួនលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ។[18] បទល្មើសដែលមានចែងក្នុងផ្នែកនេះ ដែលប្រព្រឹត្តតាមផ្លូវសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន។[19]

ច្បាប់ជាធរមានទាំងនេះ នឹងអាស្រ័យលើការសម្រេចចិត្តរបស់អាជ្ញាធរដើម្បីកំណត់ ថាតើនរណាម្នាក់បំពានច្បាប់ទាំងនេះឬអត់។ ជារឿយៗបង្ហាញថាទោះបីជាករណីតូចតាចក្តី ក៏អាជ្ញាធរគិត

---

[14] ប្រកាសអន្តរក្រសួងស្តីពី ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ប្រការ៧

[15] ប្រកាសអន្តរក្រសួងស្តីពី ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ប្រការ៨

[16] មាត្រា៣០៦ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[17] មាត្រា៤៩៤ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[18] មាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[19] មាត្រា៤៩៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ថាជាករណីបំពានច្បាប់ដែរ។ ដូច្នេះមនុស្សជាច្រើនអាចត្រូវបានគេកំណត់ជាមុខសញ្ញា និងចាប់ខ្លួនពីបទចូលរួមសកម្មភាពស្របច្បាប់តាមអ៊ិនធឺណិត។

តាមរយៈច្បាប់ជាធរមានដែលមានលក្ខណៈរឹតត្បិតទាំងនេះ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជាប្រឈមនឹងបញ្ហាទាក់ទងនឹង៖

- ការយាយី និងការជ្រៀតជ្រែកតាមផ្លូវតុលាការចំពោះអ្នកសារព័ត៌មាន



- ការដកហូតអាជ្ញាប័ណ្ណរបស់ស្ថាប័នផ្សព្វផ្សាយព័ត៌មាន



- ការបិទគេហទំព័រផ្សព្វផ្សាយព័ត៌មាន




- ការបិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ




- ការវាយប្រហារលើអ្នកសារព័ត៌មាន ឬសកម្មជនប្រឆាំង ដោយកង្វះនូវដំណោះស្រាយ



- ការដាក់ពន្ធនាគារដល់ជនទាំងឡាយណាដែលបានអនុវត្តន៍សេរីភាពខាងការបញ្ចេញមតិ



- ការពន្យាពេលក្នុងការទទួលបានយុត្តិធម៌



## ៥ .ហេតុអ្វីការទទួលបានប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមានសារៈសំខាន់ ?

ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អនុញ្ញាតឱ្យប្រជាពលរដ្ឋគ្រប់រូបបានដឹងពីរបៀបនៃការសម្រេចរបស់រដ្ឋាភិបាលដែលធ្វើឱ្យមានផលប៉ះពាល់ដល់ពួកគេ ហើយនេះក៏ជាចំណែកមួយក្នុងការជម្រុញឱ្យប្រជាពលរដ្ឋដើរតួនាទីជាអ្នកឃ្លាំមើលប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក៏ជួយបុគ្គលគ្រប់រូបឱ្យធ្វើការសម្រេចចិត្តដោយផ្អែកលើទិន្នន័យ និងព័ត៌មានត្រឹមត្រូវដែលចាំបាច់ដើម្បីរកឱ្យឃើញនូវការរំលោភសិទ្ធិមនុស្ស និងការការពារសិទ្ធិទាំងនោះ ហើយបង្កើត និងគាំទ្រការអនុវត្តតាមបែបប្រជាធិបតេយ្យ និងការអនុវត្តអភិបាលកិច្ចដែលមានការចូលរួម។[20]




លើសពីនេះទៀត ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យជួយ៖

- លុបបំបាត់អំពើពុករលួយ
- ធ្វើឱ្យរដ្ឋាភិបាលមានទំនួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន
- ជូនដំណឹងដល់ពលរដ្ឋតាមរយៈការផ្តល់ព័ត៌មានពិត និងព័ត៌មានដែលអាចទុកចិត្តបាន
- ផ្តល់វេទិកាសម្រាប់ការជជែកវែកញែក
- ផ្តល់វេទិកាសម្រាប់ការជជែកវែកញែក
- បង្ហាញពីការរំលោភសិទ្ធិមនុស្ស

----ចប់----

[20] អង្គការមាត្រា១៩ សិទ្ធិទទួលបានព័ត៌មាន ទំព័រ១ (២០១៨)